# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលការអនុវត្ត របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

★★★★★

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យ ក្នុងវិស័យអប់រំ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០២

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកែសំរួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការដែលបានចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ តាមប្រព័ន្ធបៀវត្សចាស់ និងការអនុវត្តប្រាក់សោធនចំពោះមន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈតាមប្រព័ន្ធបៀវត្សថ្មី ដោយអនុលោមតាមខ្លឹមសារព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងារ របស់មន្ត្រីរាជការស៊ីវិល និងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ "។

## ជំពូកទី ២

## ការអនុវត្តប្រាក់សោធនក្នុងប្រព័ន្ធបៀវត្សចាស់

**មាត្រា ២.-**

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនគិតតាមប្រព័ន្ធបៀវត្សចាស់ មកដល់ត្រឹមថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០២ ត្រូវបានកែសំរួលប្រាក់សោធនប្រចាំខែអោយដូចប្រាក់សោធន នៃមន្ត្រីរាជការចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ តាមប្រព័ន្ធបៀវត្សថ្មីដែរ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅ ។ ប្រាក់សោធនប្រចាំខែម្នាក់ៗ ដែលគិតតាមប្រព័ន្ធបៀវត្សថ្មី មិនត្រូវទាបជាងប្រាក់សោធនគិតតាមប្រព័ន្ធបៀវត្សចាស់ ដែលសាមីជនកំពុងទទួលឡើយ ។ ក្នុងករណីទាបជាង ត្រូវផ្តល់ប្រាក់បង្គ្រប់ជូនសាមីជននោះ ។

## ជំពូកទី ៣

## ការអនុវត្តប្រាក់សោធនតាមប្រព័ន្ធបៀវត្សថ្មី

**មាត្រា ៣.-**

ប្រាក់សោធនប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ ការផ្តល់ប្រាក់សោធន ត្រូវគណនាតាមបៀវត្សមូលដ្ឋានប្រចាំខែចុងក្រោយ នៃមន្ត្រីរាជការស៊ីវិលទាំងនោះ។

ប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់ៗ ត្រូវបានគិតបន្ថែមប្រាក់ហានិភ័យ និងប្រាក់វិភាជន៍គ្រួសារ ។ ប្រាក់វិភាជន៍សំរាប់កូនក្នុងបន្ទុកត្រូវផ្តល់ជូនរហូតដល់អាយុ១៩ ឆ្នាំ ។ ការផ្តល់ជូននេះ អាចបន្តរហូតដល់អាយុ ២១ ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា។

ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត មិនត្រូវបានរាប់បញ្ចូលឡើយ ។

របៀបគណនាប្រាក់សោធនត្រូវរក្សាទុកដូចមានចែងក្នុងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះ មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៤.-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ នៅពេលគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានផ្តល់សៀវភៅបើកប្រាក់សោធន ប្រចាំខែ ដូចមន្ត្រីរាជការដទៃទៀតដែរ ។ ប៉ុន្តែប្រាក់សោធននេះមិនត្រូវបានបើកផ្តល់ជូនទេ ក្នុងរយៈពេលកាន់មុខតំណែងជាអ្នកនយោបាយ ។ ក្រោយពេលបញ្ចប់មុខតំណែងជាអ្នកនយោបាយ សាមីជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីត្រៀមលក្ខណៈបើកផ្តល់ប្រាក់សោធនជាប្រចាំខែចាប់ពីពេលបញ្ចប់មុខតំណែងតទៅ ។

និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងទទួលប្រាក់សោធនប្រចាំខែ ហើយមានប្រាក់ឧបត្ថម្ភក្នុងមុខតំណែងជាអ្នកនយោបាយ ត្រូវផ្អាកការបើកប្រាក់សោធន ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន ។ ប្រាក់សោធននេះត្រូវបន្តបើកផ្តល់ជូនចាប់ពីពេលបញ្ចប់មុខតំណែងជាអ្នកនយោបាយ ហើយត្រូវជូនដំណឹងទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដូចវាក្យខ័ណ្ឌទី១ ខាងលើដែរ ។

ប្រាក់សោធនប្រចាំខែ ដែលត្រូវផ្អាកក្នុងរយៈពេលកាន់មុខតំណែងជាអ្នកនយោបាយ មិនត្រូវបានគិតប្រាក់រំលឹកជូនសាមីជនឡើយ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ ✓